**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអភិវឌ្ឍន៍ជនបទ**
**មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ**
**ក្រុមលទ្ធកម្ម**
លេខ ÷........../២០១៧ មអជ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការអញ្ជើញចូលរួមដេញថ្លៃការងារជួសជុលផ្លូវក្រាលកៅស៊ូ DBST ចំនួន ០១ខ្សែ ប្រវែងសរុប ១,៩០០ម៉ែត្រ ទទឹងខ្នងលើ ០៥ម៉ែត្រ និងចិញ្ចើមសងខាង ០,៥០ម៉ែត្រ ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ ប្រចាំឆ្នាំ២០១៧

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ សូមជូនដំណឹងដល់បណ្តាក្រុមហ៊ុន/សហគ្រាស (គិតទាំងសហគ្រាសឯកត្តបុគ្គល) ទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវក្នុងព្រះរាជាណាចក្រកម្ពុជាអោយបានជ្រាបថា មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ នឹងដាក់ឱ្យដេញថ្លៃជាសាធារណៈ ដើម្បីជ្រើសរើសអ្នកទទួលការ ធ្វើការងារជួសជុលផ្លូវក្រាលកៅស៊ូ DBST ចំនួន ០១ខ្សែ ប្រវែងសរុប ១,៩០០ម៉ែត្រ ទទឹងខ្នងលើ ០៥ម៉ែត្រ និងចិញ្ចើមដីសង្ខាង ០,៥០ម៉ែត្រ ចាប់ពីផ្លូវកៅស៊ូភូមិត្រពាំងសុក ដល់ភូមិព្រៃចំបក់ ឃុំតាំងយ៉ាប ស្រុកព្រៃកប្បាស ខេត្តតាកែវ ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ ប្រចាំឆ្នាំ២០១៧។

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ បានរៀបចំឯកសារសម្រាប់ក្រុមហ៊ុន/សហគ្រាសបំពេញដើម្បីចូលរួមដេញថ្លៃ។ ឯកសារដេញថ្លៃ មានដាក់លក់នៅអង្គភាពលទ្ធកម្មនៃមន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ ដែលមានអាសយដ្ឋាននៅភូមិចក សង្កាត់រកាក្នុង ក្រុងដូនកែវ ខេត្តតាកែវ ចាប់ពីថ្ងៃទី២៤ ខែមិនា ឆ្នាំ២០១៧ ... ក្នុងម៉ោងធ្វើការ (ទូរស័ព្ទទាក់ទងលេខ ០១៦ ៨២៣ ៤១៧/០៣២ ៩៣១ ១៦៣)។

ឯកសារដេញថ្លៃដែលបានបំពេញរួច ត្រូវប្រគល់ជូនអង្គភាពលទ្ធកម្ម យ៉ាងយូរបំផុតត្រឹមថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧ វេលាម៉ោង ០៨ម៉ោង៣០............។

អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

ការបើកសំណើដេញថ្លៃ នឹងប្រព្រឹត្តទៅនៅអង្គភាពលទ្ធកម្ម តាមអាសយដ្ឋានខាងលើ វេលាម៉ោង០៨ម៉ោង៣០ ថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៧។

ក្រុមហ៊ុន/សហគ្រាសដែលមានសម្ព័ន្ធភាពជាមួយគ្នា ឬមានប្រភពតែមួយ អាចដាក់សំណើដេញថ្លៃបានតែមួយគត់។

ក្រុមហ៊ុន/សហគ្រាសដែលមានបំណងចូលរួមដេញថ្លៃ សូមអញ្ជើញទាក់ទងជាមួយអង្គភាពលទ្ធកម្ម ដើម្បីទិញឯកសារដេញថ្លៃ និងសាកសួរព័ត៌មាន ដែលទាក់ទងនឹងការដេញថ្លៃនេះ។

ធ្វើនៅខេត្តតាកែវ, ថ្ងៃទី០៣ ខែមិនា ឆ្នាំ២០១៧
**ប្រធានក្រុមលទ្ធកម្ម និងជាប្រធានមន្ទីរ**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តតាកែវ

**លីវ សំណាង**

ចម្លងជូន ÷
- ក្រសួងអភិវឌ្ឍន៍ជនបទ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ)
- អង្គភាពប្រឆាំងអំពើពុករលួយ
- មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ឯកសារ-កាលប្បវត្តិ